00225081

**Declassified to Public**
**06 September 2012**

D99/3/15

**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| សំណុំរឿងលេខ ៖ | ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស. (អបជ០២) |
| ដាក់ទៅ ៖ | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: ៖ | ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០០៨ |
| ភាគីអ្នកដាក់ ៖ | សហមេធាវីរបស់លោក **អៀង សារី** |
| ភាសាដើម ៖ | អង់គ្លេស (ឯកសារដើម) |
| ប្រភេទឯកសារ ៖ | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 09 / 2008
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [signature]

---

**សំណើរបស់ អៀង សារី សុំកែប្រែសំណើជាបន្ទាន់របស់គាត់ ដើម្បីដាក់សារណាស្តីពីការអនុវត្តន៍នៃការទទួលខុសត្រូវនៃសហកម្មវត្ថុកិច្ចឧក្រិដ្ឋកម្មរួមនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់នៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ**

---

**អ្នកដាក់ឯកសារ:**

**សហមេធាវី:**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 09 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ**

**ចៅក្រម:**
លោក ប្រាក់ គឹមសាន
លោក ន័យ ថុល
លោក ហួត វុទ្ធី
លោកស្រី Katinka LAUHUIS
លោក Rowan DOWNING

**សហព្រះរាជអាជ្ញា:**
អ្នកស្រី ជា លាង
លោក Robert PETIT

[signature]

តាមរយៈសហមេធាវីរបស់គាត់ (**"មេធាវីការពារលោក អៀង សារី"**) តាមរយៈនេះ លោក **អៀង សារី** សូមដាក់សំណើសុំកែប្រែសំណើជាបន្ទាន់របស់គាត់ ដើម្បីដាក់សារណាស្តីពីការអនុវត្តន៏ការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងបណ្តឹងឧទ្ធរណ៏របស់សហព្រះរាជអាជ្ញា ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ករណីកាំង ហ្កេកអ៊ាវ ("ហៅថា ឌុច") ដែលដាក់នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៨[1]។

## I. សេចក្តីផ្តើម

1. ក.ស.ព. ដាក់បណ្តឹងឧទ្ធរណ៏ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ក.ស.ច.ស. កាលពីថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០០៨[2]។ មេធាវីការក្តីរបស់ **អៀង សារី** បានដាក់សំណើសុំដាក់សារណាឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៏របស់សហព្រះរាជអាជ្ញា នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៨។ កាលបរិច្ឆេទចុងក្រោយដើម្បីដាក់សារណាដែលបានស្នើសុំ គឺ ១៥ ថ្ងៃ បន្ទាប់ពីចេញសេចក្តីសម្រេចលើសំណើសុំ[3]។ បន្ទាប់ពីដាក់សំណើសុំ អង្គបុរេជំនុំជម្រះបានអញ្ជើញ "សាស្ត្រាចារ្យ Antonio Cassesse [...] ព្រមទាំងសមាជិកនៃក្រុមប្រឹក្សានិពន្ធផ្សេងទៀត និង គណៈកម្មាធិការនិពន្ធនាយកនៃទនានុប្បវត្តិនៃតុលាការយុត្តិធម៏ព្រហ្មទណ្ឌអន្តរជាតិ ឱ្យដាក់សារណាជាលាយលក្ខណ៏អក្សរ មិនលើសចំនួនសាម

---

1 ករណីកាំង ហ្កេអ៊ាវ (ហៅ "ឌុច") សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ០២), សំណើជាបន្ទាន់របស់លោក អៀង សារី សុំដាក់សារណាស្តីពីការអនុវត្តន៏ការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មនៅក្នុងបណ្តឹងឧទ្ធរណ៏របស់សហព្រះរាជអាជ្ញា ជំទាស់នឹងដីកាបញ្ជូនរឿងទៅជម្រះករណី កាំង ហ្កេកអ៊ាវ (ហៅ "ឌុច") ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០៨ ("សំណើ")

2 ករណីកាំង ហ្កេអ៊ាវ (ហៅ "ឌុច") សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ០២) បណ្តឹងឧទ្ធរណ៏របស់សហព្រះរាជអាជ្ញាជំទាស់នឹងដីកាបញ្ជូនរឿងទៅជម្រះករណី កាំង ហ្កេកអ៊ាវ (ហៅ "ឌុច") ចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០០៨។

3 សំណើ កថាខណ្ឌ ៨ ។

00225083



សិប (៣០) ទំព័រ ជាភាសាអង់គ្លេស និង/ឬ ជាភាសាបារាំង ចំពោះបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម ដូចដែលបានរៀបរាប់នៅក្នុងសេចក្តីអញ្ជើញនេះ ឱ្យបានត្រឹមថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៨"[4]។

2. រាល់មូលហេតុដូចដែលមានបញ្ជាក់ជូននៅខាងក្រោមនេះ មេធាវីការពារស្នើសុំកែប្រែកាលបរិច្ឆេទចុងក្រោយនៃការដាក់សារណាមកថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៨ វិញ ដែលជាកាលបរិច្ឆេទដូចគ្នាសម្រាប់ដាក់សារណាជាលាយលក្ខណ៍អក្សររបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី គឺមានលក្ខណៈសមស្រប ដោយពិចារណាលើភាពស្មុគស្មាញនៃបញ្ហាជាក់លាក់ ដែលធ្វើឱ្យអង្គបុរេជំនុំជម្រះបានស្វែងរកជំនួយ។ បន្ថែមពីលើនេះ វានឹងមិនបង្កការពន្យារពេល ឬ ធ្វើឱ្យអន្តរាយដល់ភាគីនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាដទៃទៀតឡើយ ។

## II. ច្បាប់

3. វិធាន ៣៣(២)[5] នៃវិធានផ្ទៃក្នុង ចែងថា ៖

> "លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង និង ស្របតាមសេចក្តីណែនាំអនុវត្ត ចៅក្រមអាចកំណត់ពេលវេលាសម្រាប់ដាក់សារណា សេចក្តីសន្និដ្ឋាន និង ឯកសារពាក់ព័ន្ធទៅនឹងសំណើសុំណាមួយ ឬ បណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសារទុក្ខ ដោយគិតពិចារណាដល់ កាលៈទេសៈនៃរឿងក្តីនោះ ជាពិសេស ក្នុងករណីដែលជនត្រូវចោទ ឬ ជនជាប់ចោទស្ថិតនៅក្នុង ការឃុំខ្លួនបណ្តោះអាសន្ន"។

## III. **ឧទ្ធរណ៍**

---

4 ករណីកាំង ហ្គេកអ៊ាវ (ហៅ "ឌុច") សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ០២) សេចក្តីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តី។

5 វិសោធនកម្មលើកទី ២ ចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០០៨ ។

00225084

D99/3/15



ក. ភាពស្មុគស្មាញនៃសំណួរទាំងឡាយដែលបានលើកឡើងចំពោះ*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* អនុវត្តស្មើៗ គ្នាចំពោះសារណារបស់ អៀង សារី

4 នៅក្នុងសេចក្តីអញ្ជើញ អង្គបុរេជំនុំជម្រះបានស្នើសុំឱ្យដាក់សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ទៅលើចំនុចពីរដូចខាងក្រោមនេះ ÷

១. ការអភិវឌ្ឍន៍នៃទ្រឹស្តីរបស់សហកឧក្រិដ្ឋកម្មរួម និង ការវិវត្តន៍និយមន័យនៃទម្រង់នៃការទទួលខុសត្រូវនេះ ដោយមានសេចក្តីសំអាងជាក់លាក់ទៅនឹងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

២. ថាតើសហកឧក្រិដ្ឋកម្មរួម ដែលជាទម្រង់នៃការទទួលខុសត្រូវមួយ អាចត្រូវបានយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក. បានដែរឬយ៉ាងណា ដោយការពិចារណាថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[6]។

5 ដោយមានការស្នើសុំឱ្យដាក់សារណាទៅលើចំនុចជាក់លាក់ទាំងនេះ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ភ្លាមៗនូវភាពស្មុគស្មាញនៃបញ្ហាដែលពាក់ព័ន្ធនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍នេះ។ ដោយការធ្វើបែបនេះ អង្គបុរេជំនុំជម្រះបានផ្តល់មគ្គុទ្ទេសន៏ដ៏មានសារៈប្រយោជន៏ដល់ភាគីទាំងឡាយ ហើយអាចនឹងមានអ្នកអន្តរាគមន៍នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ដូចគ្នាទៅនឹងចំនុចដែលត្រូវបានយកចិត្តទុកដាក់នៅក្នុងសារណានេះដែរ។ ដើម្បីឆ្លើយតបទៅនឹងអង្គបុរេជំនុំជម្រះឱ្យបានគ្រប់គ្រាន់ទៅលើបញ្ហាទាំងនេះ ក្រុមមេធាវីការពារក្តីរបស់ **អៀង សារី** ទាមទារឱ្យមានពេលវេលាស្មើៗគ្នាដើម្បីដាក់សារណាស្តីពីបញ្ហាទាំងឡាយ ដូចដែលបានផ្តល់ដល់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ដូច្នោះដែរ។

---

[6] លិខិតអញ្ជើញ ទំព័រទី ១ ។

៥. ការដាក់កម្រិតកាលបរិច្ឆេទចុងក្រោយត្រឹមថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៨ ដល់ក្រុមមេធាវីការពារក្ដីរបស់ អៀង សារី ដើម្បីដាក់សារណា មិនបណ្ដាលឲ្យមានការយឺតយ៉ាវដល់ការធ្វើសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ ក.ស.ព. នោះទេ។

6 នៅក្រោមវិធានផ្ទៃក្នុង ៣៣(២) ក.ស.ព. និងមេធាវីរបស់ភាគីដទៃទៀត ដូចជាដើមបណ្ដឹងរដ្ឋប្បវេណី និង មេធាវីរបស់ ឌុច ត្រូវទទួលបានផ្ដល់ឱកាសដើម្បីឆ្លើយតបទៅនឹងសារណាដែល *អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* បានដាក់ជូន។ អាស្រ័យហេតុនេះ សារណាលើបណ្ដឹងឧទ្ធរណ៍នេះនឹងបន្តយ៉ាងរលូន បន្ទាប់ពីថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៨ ដោយសារថា ភាគីទាំងអស់នឹងអាចដាក់សារណាឆ្លើយតបទៅនឹងសារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* ដែលបានដាក់ជូនដោយសាស្ត្រាចារ្យ Cassese។ អាស្រ័យហេតុនេះ ការផ្ដល់សិទ្ធិឲ្យក្រុមមេធាវីការពារក្ដីរបស់ **អៀង សារី** ទទួលបានសិទ្ធិដាក់សារណានៅកាលបរិច្ឆេទនេះ នឹងមិនបណ្ដាលឲ្យមានការយឺតយ៉ាវដល់ការធ្វើសេចក្ដីសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍នេះទេ។ ហេតុដូច្នេះ វានឹងមិនបង្កឲ្យអន្តរាយដល់ ក.ស.ព. មេធាវីការពារក្ដីរបស់ ឌុច ឬ ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

## IV. ការស្នើសុំរកភាពធូរស្រាល

**អាស្រ័យដោយ** មូលហេតុដូចបានលើកឡើងនៅទីនេះ មេធាវីការពារក្ដីសូមស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះមេត្តាផ្ដល់ពេលវេលាឲ្យ អៀង សារី រហូតដល់ថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៨ ដើម្បីដាក់សារណាជាលាយលក្ខណ៍អក្សរ នៅក្នុងការឆ្លើយតបទៅនឹងមូលហេតុទី ២ នៃបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាស្ដីពីការអនុវត្តការទទួលខុសត្រូវលើសហកម្មឧក្រិដ្ឋកម្មរួមនៅចំពោះមុខ អ.វ.ត.ក.។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៤** ខែកក្កដា ឆ្នាំ **២០០៨**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្ដម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**